# គោលដៅ និង ចំណុចដៅ
# នៃ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព កម្ពុជា (គ.អ.ច.ក.)

## គោលដៅទី១៖ បញ្ចប់ភាពក្រីក្រគ្រប់ទម្រង់នៅគ្រប់ទីកន្លែង

### ចំណុចដៅ

១.១ ត្រឹមឆ្នាំ២០៣០លុបបំបាត់ភាពក្រីក្រធ្ងន់ធ្ងរសម្រាប់ប្រជាជនគ្រប់រូបនៅគ្រប់ទីកន្លែង វាស់វែងប្រជាជនដែលរស់នៅក្នុងកម្រិតជីវភាពតិចជាង ១,៩០ដុល្លារក្នុងមួយថ្ងៃ។

១.២ កាត់បន្ថយយ៉ាងតិចពាក់កណ្ដាលនូវសមាមាត្រនៃបុរស ស្ត្រីនិងកុមារគ្រប់អាយុ ដែលរស់នៅក្នុងភាពក្រីក្រ គ្រប់សមាសភាព ដោយផ្អែកលើនិយមន័យរបស់កម្ពុជា នៅត្រឹមឆ្នាំ២០៣០។

១.៣ អនុវត្តប្រព័ន្ធជាតិគាំពារសង្គមនិងវិធានការផ្សេងៗ ឲ្យបានទូទាំងប្រទេស និងសម្រេចឲ្យបានភាគច្រើននូវភាពគ្របដណ្ដប់នៃប្រព័ន្ធនេះ ដល់ប្រជាជនក្រីក្រ និងប្រជាជនងាយរងគ្រោះ នៅត្រឹមឆ្នាំ២០៣០។

១.៤ ត្រឹមឆ្នាំ២០៣០ ធានាថា បុរស ស្ត្រីគ្រប់រូប ជាពិសេសប្រជាជនក្រីក្រនិងប្រជាជនងាយរងគ្រោះ មានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ធនធានសេដ្ឋកិច្ច និងក្នុងការទទួលបានសេវាមូលដ្ឋានភាពជាម្ចាស់ និងការគ្រប់គ្រងដីនិងកម្មសិទ្ធិផ្សេងទៀត ធនធានធម្មជាតិ បច្ចេកវិទ្យាថ្មីៗសមស្របនិងសេវាហិរញ្ញវត្ថុ រួមទាំងមីក្រូហិរញ្ញវត្ថុ។

១.៥ ត្រឹមឆ្នាំ២០៣០កសាងភាពធនរបស់ប្រជាជនក្រីក្រ និងប្រជាជនដែលរស់នៅក្នុងស្ថានភាពងាយរងគ្រោះ និងកាត់បន្ថយពីភាពងាយគ្រោះថ្នាក់និងភាពងាយរងគ្រោះពីព្រឹត្តការណ៍ធំៗពាក់ព័ន្ធនឹងអាកាសធាតុ និងការភ័យតក់ស្លុតផ្សេងទៀតដោយសារសេដ្ឋកិច្ច សង្គមកិច្ច និងបរិស្ថាន និងគ្រោះមហន្តរាយនានា។

១.a ធានាថា ការកៀរគរធនធានពីប្រភពខុសៗគ្នារួមទាំងតាមរយៈកិច្ចសហប្រតិបត្តិការសម្រាប់លើកកម្ពស់ការអភិវឌ្ឍ ដើម្បីផ្ដល់នូវមធ្យោបាយនិងការព្យាករណ៍គ្រប់គ្រាន់សម្រាប់ការអភិវឌ្ឍ

ប្រទេសជាតិនានា ជាពិសេស បណ្ដាប្រទេសដែលមានការអភិវឌ្ឍតិចតួចសម្រាប់អនុវត្តកម្មវិធីនិងគោលនយោបាយនានាដើម្បីបញ្ចប់ភាពក្រីក្រក្នុងគ្រប់រូបភាព។

១.b បង្កើតក្របខ័ណ្ឌគោលនយោបាយសមស្របនៅកម្រិតជាតិ កម្រិតតំបន់ និងកម្រិតអន្តរជាតិ ដោយផ្អែកលើយុទ្ធសាស្ត្រអភិវឌ្ឍន៍គាំទ្រប្រជាជនក្រីក្រនិងមានលក្ខណៈយេនឌ័រសម្រាប់គាំទ្រដល់ការពន្លឿនការវិនិយោគ ក្នុងផ្នែកលុបបំបាត់ភាពក្រីក្រ។

## គោលដៅទី២៖ បញ្ចប់ភាពអត់ឃ្លាន សម្រេចឲ្យបានសន្តិសុខស្បៀង ធ្វើឲ្យប្រសើរឡើងស្ថានភាពអាហារូបត្ថម្ភ និង លើកកម្ពស់កសិកម្មប្រកបដោយចីរភាព

២.១ ត្រឹមឆ្នាំ២០៣០ បញ្ចប់ភាពអត់ឃ្លាន និងធានានូវការទទួលបានស្ថានភាពនេះដោយប្រជាជនគ្រប់រូប ជាពិសេស ប្រជាជនក្រីក្រនិងប្រជាជនដែលរស់នៅក្នុងស្ថានភាពងាយរងគ្រោះ រួមទាំងកុមារ ឲ្យរួចផុតភ័យ មានម្ហូបអាហារនិងអាហារូបត្ថម្ភគ្រប់គ្រាន់ក្នុងមួយឆ្នាំៗ។

២.២ ត្រឹមឆ្នាំ២០៣០ បញ្ចប់គ្រប់ទម្រង់នៃកង្វះអាហារូបត្ថម្ភ រួមទាំងការសម្រេចបាននៅឆ្នាំ២០២៥ នូវ ចំណុចដៅដែលបានឯកភាពក្នុងកម្រិតអន្តរជាតិស្ដីពីភាពក្រិននិងភាពស្គមស្គាំងរបស់កុមារអាយុក្រោមអាយុ៥ឆ្នាំ និងដោះស្រាយនូវតម្រូវការអាហារូបត្ថម្ភរបស់កុមារីវ័យជំទង់ ស្ត្រីមានផ្ទៃពោះនិងស្ត្រីកំពុងបំបៅដោះកូន និង ស្ត្រីវ័យចាស់។

២.៣ ត្រឹមឆ្នាំ២០៣០ ទទួលបានកំណើនទ្វេរដងនៃ ផលិតផលកសិកម្ម និងចំណូលរបស់ផលិតករធុនតូច ជាពិសេស ស្ត្រីក្នុងគ្រួសារទុរគត គ្រួសារកសិករ អ្នកគង្វាលនិងអ្នកនេសាទ រួមទាំងតាមរយៈការធានានិងការទទួលបានស្មើភាពគ្នានូវដីធ្លី ធនធានផលិតកម្មផ្សេងទៀតនិងធាតុចូល ចំណេះដឹង សេវាហិរញ្ញវត្ថុ ទីផ្សារនិងកាលានុវត្តភាពសម្រាប់តម្លៃបន្ថែម និងការងារក្នុងផ្នែកមិនមែនកសិកម្ម។

២.៤ ត្រឹមឆ្នាំ២០៣០ ធានានូវប្រព័ន្ធផលិតកម្មម្ហូបអាហារដែលមានចីរភាព អនុវត្តសកម្មភាពកសិកម្មដោយមានមានការឆ្លើយតបនឹងបម្រែបម្រួលអាសធាតុ ដែលជួយឲ្យមានការកើនឡើងនូវផលិតកម្មនិផលិតផល ជួយថែរក្សាប្រព័ន្ធអេកូឡូស៊ី ជួយពង្រឹងសមត្ថភាពសម្រាប់

បន្សាំនឹងបម្រែបម្រួលអាកាសធាតុអាក្រក់ ភាពរាំងស្ងួត ទឹកជំនន់ និងគ្រោះមហន្តរាយផ្សេងទៀត និងធ្វើឲ្យប្រសើរឡើងជាបន្តបន្ទាប់គុណភាពដី។

២.៥ ត្រឹមឆ្នាំ២០២០ រក្សាការធ្វើពិពិធកម្មហ្សែននៃគ្រាប់ពូជការធ្វើកសិកម្មនិងចំការ ការផ្សាំពូជសត្វ និងប្រភេទសត្វព្រៃដែលពាក់ព័ន្ធ រួមទាំងតាមរយៈការគ្រប់គ្រងសមស្រប ការធ្វើពិពិធកម្មនិងរក្សាគ្រាប់ពូជ នៅកម្រិតជាតិ តំបន់ និងអន្តរជាតិ និងលើកកម្ពស់ការទទួលបានចំណែកប្រកបដោយយុត្តិធម៌ និងសមធម៌នៃផលប្រយោជន៍ពីការប្រើប្រាស់ធនធានហ្សែននិងចំណេះដឹងប្រពៃណីយ៍ដែលពាក់ព័ន្ធ ដូចការឯកភាពជាអន្តរជាតិ

២.a បង្កើនការវិនិយោគ រួមទាំងតាមរយៈការលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងផ្នែកហេដ្ឋារចនាសម្ព័ន្ធជនបទ ការស្រាវជ្រាវនិងសេវាផ្សព្វផ្សាយកសិកម្ម ការអភិវឌ្ឍបច្ចេកវិជ្ជានិងធនាគារហ្សែនរុក្ខជាតិនិងសត្វដើម្បីលើកកម្ពស់សមត្ថភាពផលិតក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសបណ្តាប្រទេសដែលមានការអភិវឌ្ឍតិចតួច។

២.b កែតម្រូវនិងការពារពាណិជ្ជកម្ម (ទប់ស្កាត់របាំងនិងកំហុសឆ្គងពាណិជ្ជកម្ម) ក្នុងទីផ្សារផលិតផលកសិកម្មពិភពលោក រួមទាំងការលុបបំបាត់គ្រប់ទម្រង់ទាំងអស់នៃឧបត្ថម្ភធនដល់ការនាំចេញផលិតផលកសិកម្ម និងរាល់វិធីសាស្ត្រនាំចេញដែលមានផលប៉ះពាល់ដូចគ្នាដោយផ្អែកតាមអាណត្តិកាលនៃកិច្ចប្រជុំគុម្ពលពីការអភិវឌ្ឍនៅទីក្រុងដូហា។

២.c ឯកភាពលើវិធានការណ៍នានា ដើម្បីធានាកិច្ចដំណើរការប្រសើរជាងមុននៃទីផ្សារមុខទំនិញម្ហូបអាហារនិងវត្ថុធាតុដើមសម្រាប់ផលិត និងសម្របសម្រួលឲ្យការទទួលបានទាន់ពេលវេលានូវព័ត៌មានពីទីផ្សារ រួមទាំងសេវាម្ហូបអាហារ ដើម្បីជួយទប់ស្កាត់ការប្រែប្រួលខ្លាំងក្លារបស់ថ្លៃម្ហូបអាហារ។

## គោលដៅទី៣៖ ធានាឲ្យជីវភាពរស់នៅរបស់ប្រជាជនប្រកបដោយសុខភាពល្អ និងលើកកម្ពស់សុខមាលភាពរបស់មនុស្សគ្រប់រូបនិងគ្រប់វ័យ

៣.១ កម្រិតនៃការអភិវឌ្ឍនៃប្រទេសកម្ពុជា៖ សុខភាពនិងសុខមាលភាពរបស់ប្រជាពលរដ្ឋ និងបង្ការហានិភ័យហិរញ្ញវត្ថុ។

៣.១ ត្រឹមឆ្នាំ២០៣០ កាត់បន្ថយអត្រាមរណៈភាពមាតានៅកម្រិតសាកល ឲ្យនៅកម្រិតទាបជាង ៧០ក្នុងចំណោម ១០០ ០០០កំណើតរស់។

៣.២ ត្រឹមឆ្នាំ២០៣០ បញ្ចប់ការស្លាប់ដែលអាចការពារបាន នៃទារកទើបកើតនិងកុមារអាយុក្រោម ៥ឆ្នាំ ដោយគ្រប់ប្រទេសទាំងអស់មានគោលដៅកាត់បន្ថយមរណភាពទារកទើបកើត ដល់ត្រឹម ១២ ក្នុង ១០០០កំណើតរស់ និងមរណភាពកុមារក្រោមអាយុ ៥ឆ្នាំ យ៉ាងហោចណាស់ដល់ត្រឹម ២៥ ក្នុងចំណោម ១០០០កំណើតរស់។

៣.៣ ត្រឹមឆ្នាំ២០៣០ បញ្ចប់ការរីករាលដាលមេរោគអេដស៍ ជំងឺរបេង គ្រុនចាញ់ ជំងឺមិនត្រូវបានយកចិត្តទុកដាក់នៅតំបន់ត្រូពិច ជំងឺថ្លើម ជំងឺឆ្លងតាមទឹក និងជំងឺឆ្លងផ្សេងទៀត។

៣.៤ ត្រឹមឆ្នាំ២០៣០ កាត់បន្ថយឲ្យបានមួយភាគបីនៃមរណៈភាពមុនអាយុកាលរំពឹងទុក ពីជំងឺមិនឆ្លង តាមរយៈ ការការពារនិងការព្យាបាល និងលើកកម្ពស់សុខភាពផ្លូវចិត្តនិងសុខុមាលភាព។

៣.៥ ពង្រឹងការបង្ការនិងការព្យាបាលការសេពសារធាតុរួមទាំង ការសេពគ្រឿងញៀន និងការប្រើប្រាស់ជាតិសុរាដែលនាំឲ្យគ្រោះថ្នាក់។

៣.៦ ត្រឹមឆ្នាំ២០២០ កាត់បន្ថយឲ្យបានពាក់កណ្តាលនៃចំនួនមនុស្សស្លាប់ដោយគ្រោះថ្នាក់ចរាចរនៅទូទាំងពិភពលោក។

៣.៧ ត្រឹមឆ្នាំ២០៣០ ធានាថា ការទទួលបានជាសាកលនូវសេវាថែទាំសុខភាពផ្លូវភេទ និងសេវាសុខភាពបន្តពូជ រួមទាំងផែនការគ្រួសារ ព័ត៌មាននិងការអប់រំ និងការធ្វើសមាហរណកម្មសុខភាពបន្តពូជទៅក្នុងកម្មវិធីនិងយុទ្ធសាស្រ្តជាតិ។

៣.៨ សម្រេចឲ្យបាន នូវសុខភាពល្អជាសកល រួមទាំង ការបង្ការហានិភ័យផ្នែកហិរញ្ញវត្ថុ ការទទួលបាននូវសេវាថែទាំសុខភាពចាំបាច់ដែលមានគុណភាព និង ការទទួលបានថ្នាំពេទ្យនិងថ្នាំបង្ការចាំបាច់ដែលមានគុណភាព មានប្រសិទ្ធភាពនិងសុវត្ថិភាព សម្រាប់ប្រជាជនគ្រប់រូប។

៣.៩ ត្រឹមឆ្នាំ២០៣០ កាត់បន្ថយជាបណ្ដើរៗនូវចំនួនមនុស្សស្លាប់និងឈឺ ដោយសារជាតិគីមីនិងខ្យល់ប្រកបដោយគ្រោះថ្នាក់ ការបំពុលទឹកនិងបរិយាកាស និងការចម្លងមេរោគ។

៣.a ពង្រឹងការអនុវត្តក្របខ័ណ្ឌអនុសញ្ញារបស់អង្គការសុខភាពពិភពលោក ស្តីពីការត្រួតពិនិត្យថ្នាំជក់ ឲ្យបានហ្មត់ចត់នៅក្នុងគ្រប់ប្រទេស។

៣.b គាំទ្រដល់ការស្រាវជ្រាវនិងការអភិវឌ្ឍ វ៉ាក់សាំងនិងថ្នាំពេទ្យ សម្រាប់ជំងឺឆ្លងនិងជំងឺមិនឆ្លង ដែលមានផលប៉ះពាល់ជាដំបូងដល់បណ្តាប្រទេសកំពុងអភិវឌ្ឍ ផ្តល់នូវទទួលបាននូវថ្នាំពេទ្យ និងវ៉ាក់សាំងចាំបាច់ ដើម្បីឆ្លើយតបនឹងសេចក្តីប្រកាសទីក្រុងដាហាស្តីពីកិច្ចព្រមព្រៀងស្តីពីទស្សនវិស័យពាក់ព័ន្ធនឹងពាណិជ្ជកម្មកម្មសិទ្ធិបញ្ញា (TRIPS) និងសុខភាពសាធារណៈ ដែលបញ្ជាក់ពីសិទ្ធិរបស់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ក្នុងការប្រើប្រាស់លក្ខខណ្ឌពេញលេញនៅក្នុងកិច្ចព្រមព្រៀងស្តីពី ទិដ្ឋភាពដែលពាក់ព័ន្ធនឹងអាជីវកម្មដែលមានកម្មសិទ្ធិបញ្ញាដែលឆ្លើយតបនឹងការការពារសុខភាពសាធារណៈ និងជាពិសេស ផ្តល់នូវការទទួលបានថ្នាំពេទ្យសម្រាប់ប្រជាជនទាំងអស់។

៣.c បង្កើនជាបន្តបន្ទាប់ការវិភាជថវិកាលើវិស័យសុខាភិបាល និងជ្រើសរើសការអភិវឌ្ឍការបណ្តុះបណ្តាល និងការជួលបុគ្គលិកផ្នែកសុខាភិបាល នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ជាពិសេស នៅក្នុងបណ្តាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច និងបណ្តារដ្ឋដែនកោះតូចៗកំពុងអភិវឌ្ឍន៍។

៣.d ពង្រឹងសមត្ថភាពរបស់ប្រទេសទាំងអស់ ជាពិសេស បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ សម្រាប់ផ្តល់ព័ត៌មានជាមុន ពាក់ព័ន្ធនឹងការកាត់បន្ថយហានិភ័យ និងការគ្រប់គ្រងហានិភ័យសុខភាពនៅកម្រិតជាតិនិងកម្រិតសកល។

## គោលដៅទី៤៖ ធានាការអប់រំប្រកបដោយ គុណភាព បរិយាប័ន្ន និងសមធម៌ និងលើកកម្ពស់ឱកាសនុវត្តភាពសិក្សាពេញមួយជីវិត សម្រាប់ប្រជាជនគ្រប់រូប

៤.១ ត្រឹមឆ្នាំ២០៣០ ធានាថា កុមារានិងកុមារីទទួលបានការអប់រំពេញលេញប្រកបដោយសមធម៌ និងគុណភាព នៅកម្រិតបឋមសិក្សានិងមធ្យមសិក្សាដោយមិនមានការបង់ថ្លៃឈ្នួល ដែលនឹងធ្វើឲ្យលទ្ធផលនៃការសិក្សាមានប្រសិទ្ធភាព។

៤.២ ត្រឹមឆ្នាំ២០៣០ ធានាថា កុមារានិងកុមារីគ្រប់រូបនឹងទទួលបាននូវការអភិវឌ្ឍក្នុងភាពជាកុមារតូច ទាំងការថែរក្សានិងការអប់រំនៅមត្តេយ្យសិក្សា ប្រកបដោយគុណភាព សម្រាប់ត្រៀមខ្លួនគ្រប់គ្រាន់សិក្សានៅកម្រិតបឋមសិក្សា។

៤.៣ ត្រឹមឆ្នាំ២០៣០ ធានាការទទួលបានស្មើភាពគ្នាសម្រាប់បុរសនិងស្ត្រីគ្រប់រូប នូវការបណ្តុះបណ្តាលបច្ចេកទេសមុខវិជ្ជាជីវៈ និងការសិក្សានៅកម្រិតឧត្តមសិក្សា រួមទាំង សាកលវិទ្យាល័យ។

៤.៤ ត្រឹមឆ្នាំ២០៣០ បង្កើនជាបន្តបន្ទាប់នូវចំនួនយុវវ័យនិងប្រជាជនពេញវ័យដែលមានជំនាញរួមទាំងជំនាញបច្ចេកទេសនិងវិជ្ជាជីវៈ សម្រាប់បំពេញការងារ មុខរបរភាពជាសហគ្រិនសមរម្យ។

៤.៥ ត្រឹមឆ្នាំ២០៣០ លុបបាត់កម្លាតយេនឌ័រនៅក្នុងវិស័យអប់រំ និងធានាការទទួលបានភាពស្មើភាពគ្នាក្នុងការអប់រំគ្រប់កម្រិត និងនៅក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ក្រុមជនងាយរងគ្រោះ រួមទាំងក្រុមជនដែលបាត់បង់សមត្ថភាពពលកម្ម ប្រជាជននិងកុមារដែលរស់នៅក្នុងស្ថានភាពងាយរងគ្រោះ។

៤.៦ ត្រឹមឆ្នាំ២០៣០ ធានាថា យុវវ័យគ្រប់រូប និង~~សមាមាត្រ~~ភាគច្រើននៃប្រជាជនពេញវ័យ ទាំងបុរសនិងស្ត្រី សម្រេចបាននូវលក្ខខណ្ឌអក្ខរភាព។

៤.៧ ត្រឹមឆ្នាំ២០៣០ ធានាថា អ្នកសិក្សាគ្រប់រូប នឹងទទួលបានចំណេះដឹងនិងជំនាញដែលត្រូវការដើម្បីជំរុញការអភិវឌ្ឍប្រកបដោយចីរភាព រួមទាំងក្នុងចំណោមប្រជាជនផ្សេងទៀតតាមរយៈការសិក្សាសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនិងជីវភាពពរស់នៅដោយចីរភាព មានសិទ្ធិមនុស្ស មានសមភាពយេនឌ័រ មានលើកកម្ពស់វប្បធម៌សន្តិភាពនិងគ្មានអំពើហិង្សា ប្រជាជាតិនិងការលើកទឹកចិត្តជាសាកលនៃវប្បធម៌ចម្រុះ និងការរួមចំណែករបស់វប្បធម៌ទៅដល់ការអភិវឌ្ឍប្រកបដោយចីរភាព។

៤.a កសាងនិងធ្វើឲ្យប្រសើរឡើងសម្ភារៈបរិក្ខាអប់រំ ដែលធ្វើឲ្យមានភាពប្រែប្រួលដល់កុមារអ្នកបាត់បង់សមត្ថភាពពលកម្មនិងយេនឌ័រ និងផ្តល់នូវសុវត្ថិភាព គ្មានអំពើហិង្សា មានបរិស្ថាននៃការសិក្សាប្រកបដោយបរិយាប័ន្ននិងមានប្រសិទ្ធភាព សម្រាប់ប្រជាជនគ្រប់រូប។

៤.b ត្រឹមឆ្នាំ២០២០ ពង្រីកជាបន្តបន្ទាប់នូវចំនួនអាហារូបករណ៍ក្នុងសាកលលោកសម្រាប់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេស បណ្តាប្រទេសដែលមានការអភិវឌ្ឍតិចតួច បណ្តារដ្ឋដែនកោះតូចៗកំពុងអភិវឌ្ឍន៍ បណ្តាប្រទេសក្នុងទ្វីបអាហ្វ្រិក សម្រាប់ការសិក្សានៅកម្រិតខ្ពស់ រួមទាំង ការបណ្តុះបណ្តាលវិជ្ជាជីវៈ និង បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ កម្មវិធីបច្ចេកទេស វិស្វករនិងវិទ្យាសាស្ត្រ នៅក្នុងបណ្តាប្រទេសអភិវឌ្ឍន៍និងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងទៀត។

៤.c ត្រឹមឆ្នាំ២០៣០ បង្កើនឲ្យបានច្រើនការផ្គត់ផ្គង់គ្រូបង្រៀនដែលមានគុណភាព រួមទាំងតាមរយៈ កិច្ចសហប្រតិបត្តិការអន្តរជាតិ សម្រាប់ការបណ្តុះបណ្តាលគ្រូបង្រៀននៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេស បណ្តាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច និងក្នុងបណ្តារដ្ឋដែនកោះតូចៗកំពុងអភិវឌ្ឍន៍។

## គោលដៅទី៥៖ សម្រេចឲ្យបានសមភាពយេនឌ័រ និងពង្រឹងភាពអង់អាចរបស់ស្ត្រី និងកុមារីគ្រប់រូប

៥.១ បញ្ចប់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីនិងកុមារី នៅគ្រប់ទីកន្លែង។

៥.២ លុបបំបាត់រាល់ទម្រង់នៃអំពើហិង្សាលើស្ត្រីនិងកុមារី នៅទីសាធារណៈនិងទីកន្លែងឯកជននានា រួមទាំងការជួញដូរ ការធ្វើអាជីវកម្មផ្លូវភេទនិងអាជីវកម្មផ្សេងទៀត។

៥.៣ លុបបំបាត់រាល់ទង្វើដែលមានគ្រោះថ្នាក់ ដូចជាការបង្ខំកុមារឲ្យរៀបអាពាហ៍ពិពាហ៍ និងការធ្វើឲ្យមានរបួសស្នាមប្រដាប់បន្តពូជ។

៥.៤. ទទួលស្គាល់និងផ្តល់តម្លៃដល់ការងារផ្ទះដែលមិនទទួលកម្រៃ តាមរយៈ ការផ្តល់សេវាសាធារណៈ ហេដ្ឋារចនាសម្ព័ន្ធ និងគោលនយោបាយគាំពារសង្គម និងលើកកម្ពស់ការរួមចំណែកទទួលខុសត្រូវឲ្យបានសមរម្យ នៅក្នុងសង្គមគ្រួសារនិងសង្គមជាតិ។

៥.៥ ធានាការចូលរួមពេញលេញនិងមានប្រសិទ្ធភាពរបស់ស្ត្រី និងមានឱកាសដូចគ្នាក្នុងភាពជាអ្នកដឹកនាំនៅគ្រប់កម្រិតនៃការធ្វើសេចក្តីសម្រេចក្នុងវិស័យនយោបាយ សេដ្ឋកិច្ច និងជីវិតជាសាធារណៈ។

៥.៦ ធានាការទទួលបានសុខភាពផ្លូវភេទនិងសុខភាពបន្តពូជ និងសិទ្ធិបន្តពូជជាសកលដូចបានឯកភាពដោយផ្អែកលើកម្មវិធីសកម្មភាពរបស់សន្និសីទអន្តរជាតិស្តីពីប្រជាជននិងការអភិវឌ្ឍ និងផែនការ សកម្មភាពទីក្រុងប៉េកាំង និងឯកសារពាក់ព័ន្ធនានា។

៥.a ដំណើរការកំណែទម្រង់ ដើម្បីផ្តល់ដល់ស្ត្រីនូវសិទ្ធិស្មើភាពគ្នា លើធនធានសេដ្ឋកិច្ច ក៏ដូចជាការទទួលបានភាពជាម្ចាស់និងការគ្រប់គ្រងដីនិងអចលនទ្រព្យផ្សេងទៀត សេវាកម្មហិរញ្ញវត្ថុ ធនធានធម្មជាតិនិងមរតក ដោយផ្អែកលើច្បាប់របស់ប្រទេស។

៥.b បង្កើនការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ ដើម្បីលើកកម្ពស់ភាពអង់អាចដល់ស្ត្រី។

៥.C អនុម័តនិងពង្រឹងគោលនយោបាយនិងបទដ្ឋានគតិយុត្តិនានា សម្រាប់លើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រីនិងកុមារី នៅគ្រប់កម្រិត។

## គោលដៅទី៦៖ ធានាឲ្យមានទឹកនិងអនាម័យ និងការគ្រប់គ្រងទឹកនិងអនាម័យប្រកបដោយចីរភាព សម្រាប់ប្រជាជនគ្រប់រូប

៦.១ ត្រឹមឆ្នាំ២០៣០ សម្រេចនូវការទទួលបានសាកលកម្មនិងសមធម៌នូវទឹកបរិភោគដែលមានសុវត្ថិភាពនិងតម្លៃសមរម្យ សម្រាប់ប្រជាជនទាំងអស់។

៦.២ ត្រឹមឆ្នាំ២០៣០ សម្រេចនូវការទទួលបានគ្រប់គ្រាន់និងសមធម៌នូវអនាម័យ សម្រាប់ប្រជាជនគ្រប់រូប និងបញ្ចប់ការបន្ទោរបង់នៅក្រៅបង្គន់ ផ្តោតការយកចិត្តទុកដាក់លើតម្រូវការរបស់ស្ត្រី និងកុមារី និងប្រជាជនដែលរស់នៅក្នុងស្ថានភាពងាយរងគ្រោះ។

៦.៣ ត្រឹមឆ្នាំ២០៣០ ធ្វើឲ្យប្រសើរឡើងគុណភាពទឹក ដោយកាត់បន្ថយការបំពុល លុបបំបាត់ការបោះបង់សំរាម និងកាត់បន្ថយឲ្យនៅកម្រិតទាបបំផុតនៃការបោះបង់ចោលសម្ភារៈនិងសារធាតុជាតិគីមីដែលមានគ្រោះថ្នាក់ កាត់បន្ថយឲ្យនៅពាក់កណ្ដាលសមាមាត្រនៃសំណល់រាវដែលមិនបានសម្អាត និងបង្កើនឲ្យបានច្រើនវត្ថុធាតុដើមកកើតឡើងវិញ និងការប្រើប្រាស់ឡើងវិញប្រកបដោយសុវត្ថិភាពជាសកល។

៦.៤ ត្រឹមឆ្នាំ២០៣០ បង្កើនឲ្យបានច្រើននូវប្រសិទ្ធភាពនៃទឹកដែលប្រើប្រាស់នៅគ្រប់វិស័យ និងធានានូវការបូមនិងផ្គត់ផ្គង់ទឹកសាប ដើម្បីដោះស្រាយការខ្វះខាតទឹក និងកាត់បន្ថយឲ្យបានច្រើននូវចំនួនប្រជាជនដែលរងគ្រោះដោយសារការខ្វះខាតទឹក។

៦.៥ ត្រឹមឆ្នាំ២០៣០ អនុវត្តការគ្រប់គ្រងការធ្វើសមាហរណកម្មធនធានទឹកនៅគ្រប់កម្រិត រួមទាំងតាមរយៈ កិច្ចសហប្រតិបត្តិការឆ្លងកាត់ព្រំដែនឲ្យបានសមរម្យ។

៦.៦ ត្រឹមឆ្នាំ២០២០ការពារនិងធ្វើឲ្យមានទឹកឡើងវិញ ពាក់ព័ន្ធនឹងប្រព័ន្ធអេកូឡូស៊ី រួមទាំង ភ្នំ ព្រៃ ដីសើម ទន្លេ និងបឹង។

៦.a ត្រឹមឆ្នាំ២០៣០ ពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិ និងគាំទ្រការកសាងសមត្ថភាពដល់បណ្ដាប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងកម្មវិធីនិងសកម្មភាពពាក់ព័ន្ធនឹងទឹកនិងអនាម័យ រួមទាំង បច្ចេកវិជ្ជា ប្រមូលទឹក បន្សាបទឹកប្រៃប្រសិទ្ធភាពទឹក សម្អាតសំណល់រាវ កែច្នៃនិងប្រើប្រាស់ឡើងវិញ។

៦.b គាំទ្រនិងពង្រឹងការចូលរួមរបស់សហគមន៍មូលដ្ឋាន ក្នុងការធ្វើឲ្យប្រសើរឡើងការគ្រប់គ្រងទឹកនិងអនាម័យ។

## គោលដៅទី៧៖ ធានាឲ្យទទួលបានថាមពលដែលមានបច្ចេកទេសទំនើបប្រកបដោយចីរភាព អាចជឿជាក់បាន និងមានតម្លៃសមរម្យ សម្រាប់ប្រជាជនគ្រប់រូប

៧.១ ត្រឹមឆ្នាំ២០៣០ ធានាការទទួលបានជាសាកលនូវសេវាថាមពលទំនើប អាចទុកចិត្តបាន និងតម្លៃសមរម្យ។

៧.២ ត្រឹមឆ្នាំ២០៣០ បង្កើនចំណែកនៃថាមពលកកើតឡើងវិញក្នុងថាមពលចម្រុះជាសាកល។

៧.៣ ត្រឹមឆ្នាំ២០៣០ បង្កើនទ្វេដងនៃអត្រាធ្វើឲ្យប្រសើរឡើងនូវប្រសិទ្ធភាពថាមពលជាសកល។

៧.a ត្រឹមឆ្នាំ២០៣០ លើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីសម្របសម្រួលការទទួលបាន បច្ចេកវិទ្យានិងការស្រាវជ្រាវពីថាមពលស្អាត រួមទាំង ថាមពលកកើតឡើងវិញ ប្រសិទ្ធភាពថាមពល និងបច្ចេកវិទ្យាឥន្ធនៈ ហ្វូស៊ីលស្អាត និងជំរុញការវិនិយោគក្នុងផ្នែកហេដ្ឋារចនាសម្ព័ន្ធថាមពលនិងបច្ចេកវិទ្យា ថាមពលស្អាត។

៧.b ត្រឹមឆ្នាំ២០៣០ ពង្រីកហេដ្ឋារចនាសម្ព័ន្ធ និងបង្កើនសមត្ថភាពបច្ចេកទេសសម្រាប់ការផ្គត់ផ្គង់ សេវាថាមពលដែលមានលក្ខណៈទំនើបនិងចីរភាព សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ទាំងអស់ ជាពិសេស បណ្តាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច រដ្ឋជាដែនកោះតូចៗកំពុងអភិវឌ្ឍន៍ និង បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ពុំមានព្រំដែនជាប់សមុទ្រ ស្របទៅតាមកម្មវិធីសម្រាប់ការគាំទ្ររបស់ប្រទេសនីមួយៗ។

## គោ លដៅទី៨៖ ធានាកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពនិងបរិយាប័ន្ន មានមុខរបរពេញលេញ និងផលិតភាព និងមានការងារសមរម្យ សម្រាប់ប្រជាជនគ្រប់រូប

៨.១ រក្សាស្ថិរភាពកំណើនសេដ្ឋកិច្ចសម្រាប់មនុស្សម្នាក់ឲ្យស្របតាមលក្ខខណ្ឌជាតិ ជាពិសេសកំណើន ផលិតផលក្នុងស្រុកសរុបប្រចាំឆ្នាំយ៉ាងតិច៧%នៅក្នុងបណ្តាប្រទេសដែលមានការអភិវឌ្ឍតិចតួច។

៨.២ សម្រេចឲ្យបានផលិតភាពសេដ្ឋកិច្ចកម្រិតខ្ពស់ជាងមុន តាមរយៈ ការធ្វើពិពិធកម្ម ការបង្កើនកម្រិតបច្ចេកវិទ្យា និងនវានុវត្តន៍ រួមទាំងតាមរយៈ ការផ្តោតការយកចិត្តទុកដាក់លើវិស័យដែលមានតម្លៃបន្ថែមខ្ពស់ និងឧស្សាហកម្មអតិពលកម្ម។

៨.៣ លើកកម្ពស់គោលនយោបាយតម្រង់ទិសការអភិវឌ្ឍដែលគាំទ្រសកម្មភាពផលិតកម្មបង្កើតការងារ សមរម្យ សហគ្រិនភាព ការច្នៃប្រឌិតនិងនវានុវត្តន៍ និងលើកទឹកចិត្តក្នុងការចុះបញ្ជី

ជាផ្លូវការ និងកំណើនសហគ្រាស មីក្រូតូចៗ និងមធ្យម រួមទាំង តាមរយៈ ការទទួលបានសេវាហិរញ្ញវត្ថុ។

៨.៤ រហូតដល់ឆ្នាំ២០៣០ ធ្វើឲ្យប្រសើរឡើងជាបន្តបន្ទាប់ ភាពស័ក្តសិទ្ធនៃធនធានជាសកលសម្រាប់ការប្រើប្រាស់និងផលិតកម្ម និងកិច្ចខិតខំប្រឹងដើម្បីបញ្ចៀស កំណើនសេដ្ឋកិច្ចមានផលប៉ះពាល់ដល់បរិស្ថាន ស្របតាមក្របខ័ណ្ឌកម្មវិធីរយៈពេល១០ឆ្នាំ ស្តីពីផលិតកម្មនិងការប្រើប្រាស់ប្រកបដោយចីរភាព ដោយនាំមុខដោយបណ្តាប្រទេសអភិវឌ្ឍ។

៨.៥ ត្រឹមឆ្នាំ២០៣០ សម្រេចឲ្យបានការងារពេញលេញប្រកបដោយផលិតភាព និងការងារសមរម្យសម្រាប់ស្ត្រីនិងបុរស រួមទាំងសម្រាប់កម្លាំងពលកម្មវ័យក្មេងនិងប្រជាជនដែលបាត់បង់សមត្ថភាពពលកម្ម និងទទួលបានប្រាក់ឈ្នួលពលកម្មស្មើគ្នាចំពោះប្រភេទពលកម្មស្មើគ្នា។

៨.៦ ត្រឹមឆ្នាំ២០២០ កាត់បន្ថយឲ្យបានច្រើននូវយុវជន ដែលគ្មានការងារធ្វើ គ្មានការអប់រំ ឬគ្មានការ បណ្តុះបណ្តាល។

៨.៧ ចាត់វិធានការនានាជាបន្ទាន់និងមានប្រសិទ្ធភាពដើម្បីលុបបំបាត់ពលកម្មដោយបង្ខំ បញ្ចប់ទាសភាពសម័យទំនើបនិងការជួញដូរមនុស្ស និងធានាការហាមឃាត់និងការលុបបំបាត់ពលកម្មកុមារដោយរួមទាំង ការជ្រើសរើសនិងប្រើប្រាស់យោធាជាកុមារ និងត្រឹមឆ្នាំ២០២៥ បញ្ចប់នូវគ្រប់ទម្រង់ទាំងអស់នៃពលកម្មកុមារ។

៨.៨ ការពារសិទ្ធិនានារបស់កុមារ និងលើកកម្ពស់សុវត្ថិភាពនិងធានាបរិស្ថានការងារសម្រាប់ពលករទាំងអស់ រួមទាំងពលករចំណាកស្រុក ជាពិសេស ជនចំណាកស្រុកជាស្ត្រី និង អ្នកដែលធ្វើការងារមិនជាប់លាប់។

៨.៩ ត្រឹមឆ្នាំ២០៣០ បង្កើតនិងអនុវត្តគោលនយោបាយ សម្រាប់លើកកម្ពស់ទេសចរណ៍ប្រកបដោយចីរភាព ដែលបង្កើតការងារនិងលើកកម្ពស់វប្បធម៌និងផលិតផលក្នុងស្រុក។

៨.១០ ពង្រឹងសមត្ថភាពរបស់ស្ថាប័នហិរញ្ញវត្ថុក្នុងស្រុក ដើម្បីលើកកម្ពស់និងពង្រីកការទទួលបានសេវាធនាគារ សេវាធានារ៉ាប់រង និងសេវាហិរញ្ញវត្ថុ សម្រាប់ប្រជាជនគ្រប់រូប។

៨.a បង្កើនហិរញ្ញប្បទានសម្រាប់គាំទ្រវិស័យពាណិជ្ជកម្មសម្រាប់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេស បណ្តាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច រួមទាំងតាមរយៈក្របខ័ណ្ឌលើកកម្ពស់ការធ្វើសមាហរណកម្មសម្រាប់ជំនួយបច្ចេកទេសពាក់ព័ន្ធនឹងពាណិជ្ជកម្មដល់បណ្តាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច។

៨.b ត្រឹមឆ្នាំ២០២០ រៀបចំនិងអនុវត្តយុទ្ធសាស្ត្រសកលសម្រាប់ការងារយុវវ័យ និងអនុវត្តកតិកាសញ្ញាសកលពីមុខរបរ របស់អង្គការពលកម្មអន្តរជាតិ។

## គោលដៅទី៩៖ កសាង ហេដ្ឋារចនាសម្ព័ន្ធដែលធន់នឹងបម្រែបម្រួលអាកាសធាតុ លើកកម្ពស់ឧស្សាហូបនីយកម្មប្រកបដោយចីរភាពនិងបរិយាប័ន្ននិង លើកកម្ពស់នវានុវត្តន៍

៩.១ អភិវឌ្ឍហេដ្ឋរចនាសម្ព័ន្ធដែលមានគុណភាព អាចជឿជាក់បាន ធននឹងបម្រែបម្រួលអាកាសធាតុ និងចីរភាព រួមទាំង ហេដ្ឋារចនាសម្ព័ន្ធតំបន់និងឆ្លងកាត់ព្រំដែនប្រទេស ដើម្បីគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចនិងជីវភាពរស់នៅរបស់ប្រជាជនប្រសើរ ជាមួយនឹងការផ្តោតការយកចិត្តទុកដាក់លើការទទួលបានដោយសមរម្យនិងសមធម៌ សម្រាប់ប្រជាជនគ្រប់រូម។

៩.២ លើកកម្ពស់ឧស្សាហូបនីយកម្មប្រកបដោយបរិយាប័ន្ននិងចីរភាព និងត្រឹមឆ្នាំ២០៣០ បង្កើនឲ្យបានច្រើន ឧស្សាហកម្មដែលរួមចំណែក បង្កើតការងារនិងផលិតផលក្នុងស្រុកសរុប ឲ្យស្របតាមកាលៈទេសៈជាតិ និងបង្កើនការរួមចំណែកនេះទ្វេដង នៅក្នុងបណ្តាប្រទេសដែលមានការអភិវឌ្ឍតិចតួច។

៩.៣ បង្កើនការទទួលបានសេវាហិរញ្ញវត្ថុ នៃឧស្សាហកម្មធុនតូចនិងសហគ្រាសផ្សេងៗទៀត ជាពិសេស នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ រួមទាំង ឥណទានសមស្របនិងការធ្វើសមាហរណកម្មឧស្សាហកម្មនិងសហគ្រាសទាំងនោះ ទៅក្នុងសង្វាក់តម្លៃនិងទីផ្សារ។

៩.៤ ត្រឹមឆ្នាំ២០៣០ បង្កើនសមត្ថភាពហេដ្ឋារចនាសម្ព័ន្ធនិងបំពាក់បន្ថែមលទ្ធភាពរបស់ឧស្សាហកម្ម ដើម្បីធ្វើឲ្យមានចីរភាព ជាមួយនឹងការបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ធនធាន និងការទទួលយកបច្ចេកវិទ្យានិងដំណើរការឧស្សាហកម្មសមស្របដែលស្អាត និងមិនប៉ះពាល់ប

វិស្ថាន ដោយគ្រប់ប្រទេសទាំងអស់ត្រូវធ្វើសកម្មភាពឲ្យស្របតាមសមត្ថភាពរបស់គេរៀងៗខ្លួន។

៩.៥ លើកកម្ពស់ការស្រាវជ្រាវវិទ្យាសាស្ត្រ បង្កើនសមត្ថភាពបច្ចេកវិទ្យារបស់វិស័យឧស្សាហកម្មនៅគ្រប់ប្រទេស ជាពិសេស បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងនោះ ត្រឹមឆ្នាំ២០៣០ លើកទឹកចិត្តនវានុវត្តន៍និងបង្កើនចំនួននៃពលករស្រាវជ្រាវនិងការអភិវឌ្ឍ ក្នុងប្រជាជន១លាននាក់ និងការចំណាយដល់ការស្រាវជ្រាវនិងការអភិវឌ្ឍផ្នែកសាធារណៈនិងឯកជន។

៩.a សម្របសម្រួលឲ្យមានការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដែលមានភាពបន្សាំ និងប្រកបដោយចីរភាព នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ តាមរយៈការលើកកម្ពស់ការគាំទ្រហិរញ្ញវត្ថុ បច្ចេកវិទ្យានិងបច្ចេកទេស ដល់បណ្តាប្រទេសនៅទ្វីបអាហ្វ្រិក បណ្តាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួចបណ្តាប្រទេសដែលពុំមានព្រំដែនជាប់សមុទ្រកំពុងអភិវឌ្ឍន៍ និងបណ្តារដ្ឋជាដែនកោះតូចៗកំពុងអភិវឌ្ឍន៍។

៩.b គាំទ្រការអភិវឌ្ឍ ការស្រាវជ្រាវ និងនវានុវត្តន៍បច្ចេកវិជ្ជាក្នុងស្រុក ក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ រួមទាំងតាមរយៈការធានានូវការអនុវត្តបរិស្ថានគោលនយោបាយសម្រាប់ ពិពិធកម្មឧស្សាហកម្មនិងការផ្តល់តម្លៃបន្ថែមដល់ទំនិញប្រើប្រាស់។

៩.c បង្កើនឲ្យបានច្រើនការទទួលបានបច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ និងខិតខំប្រឹងប្រែងផ្តល់នូវការទទួលបានឲ្យបានសមរម្យនិងជាសកលនូវសេវាអ៊ិនទ័រណិត ក្នុងបណ្តាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច ត្រឹមឆ្នាំ២០២០។

## គោលដៅទី១០៖ កាត់បន្ថយវិសមភាពនៅក្នុងប្រទេសនិងក្នុងចំណោមបណ្តាប្រទេសនានា

១០.១ ត្រឹមឆ្នាំ២០៣០ សម្រេចឲ្យបានចំណូលរបស់ប្រជាជនចំនួន ៤០%នៃប្រជាជនទាំងអស់ដែលមានចំណូលទាបជាងគេនូវកំណើនជាបន្តបន្ទាប់និងដោយចីរភាពក្នុងអត្រាខ្ពស់ជាងកម្រិតមធ្យមរបស់ជាតិ។

១០.២ ត្រឹមឆ្នាំ២០៣០ ផ្តល់ភាពអង់អាចនិងជំរុញបរិយាប័ន្នសង្គម សេដ្ឋកិច្ច និងនយោបាយ សម្រាប់ប្រជាជនគ្រប់រូប ដោយមិនគិតពីស្ថានភាព អាយុ ភេទ ការបាត់បង់សមត្ថភាពពលកម្ម ពូជសាសន៍ ជនជាតិភាគតិច ជនជាតិដើម សាសនា ឬសេដ្ឋកិច្ច ឬស្ថានភាពផ្សេងទៀត។

១០.៣ ធានាផ្តល់នូវឱកាសស្មើៗគ្នា និងកាត់បន្ថយវិសមភាពនៃលទ្ធផល រួមទាំងតាមរយៈ ការលុបបំបាត់ ច្បាប់ គោលនយោបាយ និងការអនុវត្ត ដែលមានលក្ខណៈរើសអើង និងជំរុញការរៀបចំលិខិតបទដ្ឋានគតិយុត្តិ គោលនយោបាយ និងការអនុវត្តសកម្មភាព ឲ្យបានត្រឹមត្រូវ។

១០.៤ ឯកភាពលើគោលនយោបាយនានា ជាពិសេស គោលនយោបាយស្តីពីសារពើពន្ធ ប្រាក់បៀវត្សរ៍ ការគាំពារសង្គម និង សម្រេចឲ្យបានជាបន្តបន្ទាប់សមភាពច្រើនជាងមុន។

១០.៥ ធ្វើឲ្យប្រសើរឡើងបញ្ញត្តិ និងការតាមដានស្ថាប័ននិងទីផ្សារហិរញ្ញវត្ថុសាកល និងពង្រឹងការអនុវត្តបទប្បញ្ញត្តិទាំងនេះ។

១០.៦ ធានាការលើកកម្ពស់ភាពជាតំណាងនិងសម្លេង សម្រាប់ បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ នៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត ក្នុងសេដ្ឋកិច្ចអន្តរជាតិនិងសកល និងស្ថាប័ន ហិរញ្ញវត្ថុនានា ដើម្បីផ្តល់នូវ ស្ថាប័នដែលមាន ប្រសិទ្ធភាព ភាពជឿជាក់ គណនេយ្យភាពនិងមានច្បាប់ពេញលេញ។

១០.៧ សម្របសម្រួលឲ្យប្រជាជនវ័យចាស់ ដែលធ្វើចំណាកស្រុកនិងពុំមានទីលំនៅច្បាស់លាស់មានសុវត្ថិភាព ត្រឹមត្រូវតាមច្បាប់ និងដោយទទួលខុសត្រូវរួម តាមរយៈ ការអនុវត្តផែនការនិងគោលនយោបាយផ្លាស់ប្តូរទីលំនៅដែលមានការគ្រប់គ្រងល្អ។

១០.a អនុវត្តគោលការណ៍និងប្រព្រឹត្តកម្មពិសេសនិងដោយឡែកសម្រាប់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសបណ្តាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច ឲ្យស្របតាមកិច្ចព្រមព្រៀងពាណិជ្ជកម្មពិភពលោក។

១០.b លើកទឹកចិត្តចំពោះជំនួយអភិវឌ្ឍន៍ផ្លូវការ និងលំហូរហិរញ្ញវត្ថុ រួមទាំងការវិនិយោគផ្ទាល់ពីបរទេស ដល់បណ្តារដ្ឋដែលមានតម្រូវការជាងគេ ជាពិសេសបណ្តាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច បណ្តាប្រទេសនៅក្នុងទ្វីបអាហ្វ្រិក បណ្តារដ្ឋដែនកោះតូចៗដែលកំពុងអភិវឌ្ឍន៍ និងបណ្តាប្រទេសដែលពុំមានព្រំប្រទល់ជាប់សមុទ្រកំពុងអភិវឌ្ឍន៍ ឲ្យស្របតាមផែនការនិងកម្មវិធីជាតិនានារបស់ប្រទេសនីមួយៗ។

១០.c ត្រឹមឆ្នាំ២០៣០ កាត់បន្ថយថ្លៃឈ្នួលផ្ទេរប្រាក់របស់ជនចំណាកស្រុក ឲ្យនៅទាបជាង ៣% និងលុបបំបាត់ប្រព័ន្ធផ្ទេរប្រាក់ដែលមានថ្លៃឈ្នួល ខ្ពស់ជាង៥%។

## គោលដៅទី១១៖ ធ្វើឲ្យទីក្រុង និងទីកន្លែងតាំងទីលំនៅថ្មីសម្រាប់ប្រជាជន មានលក្ខណៈ បរិយាប័ន្ន សុវត្ថិភាព ធន់នឹងបម្រែបម្រួលអាកាសធាតុនិងចីរភាព

១១.១ ត្រឹមឆ្នាំ២០៣០ ធានាឲ្យប្រជាជនគ្រប់រូបទទួលបានផ្ទះសមរម្យ សុវត្ថិភាព គ្រប់គ្រាន់ និងទទួលបានសេវាមូលដ្ឋាននិងលើកកម្ពស់ស្ថានភាពតំបន់លំនៅដ្ឋានមិនទាន់រៀបរយ។

១១.២ ត្រឹមឆ្នាំ២០៣០ ផ្តល់នូវការទទួលបានសម្រាប់ប្រជាជនគ្រប់រូប នូវប្រព័ន្ធដឹកជញ្ជូនដែលសមរម្យ សុវត្ថិភាព និងចីរភាព ធ្វើឲ្យប្រសើរឡើងសុវត្ថិភាពផ្លូវថ្នល់ ជាពិសេសពង្រីកការដឹកជញ្ជូនសាធារណៈ ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើតម្រូវការរបស់ស្ត្រី កុមារដែលរស់នៅក្នុងស្ថានភាពងាយរងគ្រោះ ប្រជាជនដែលបាត់បង់សមត្ថភាពពលកម្ម និងប្រជាជនវ័យចាស់។

១១.៣ ត្រឹមឆ្នាំ២០៣០ លើកម្ពស់នគរូបនីយកម្មប្រកបដោយបរិយាប័ន្ននិងចីរភាព សមត្ថភាពសម្រាប់ការចូលរួម រៀបចំផែនការនិងគ្រប់គ្រងការតាំងទីលំនៅថ្មីប្រកបដោយចីរភាពនិងសមាហរណកម្ម នៅគ្រប់ប្រទេស។

១១.៤ ពង្រឹងកិច្ចខិតខំប្រឹងប្រែងបង្ការនិងការពារវប្បធម៌និងមរតកធម្មជាតិរបស់ពិភពលោក

១១.៥ ត្រឹមឆ្នាំ២០៣០ កាត់បន្ថយឲ្យបានច្រើនចំនួនមនុស្សស្លាប់ ចំនួនមនុស្សដែលរងផលប៉ះពាល់ពីគ្រោះមហន្តរាយ និងកាត់បន្ថយជាបន្តបន្ទាប់ការបាត់បង់សេដ្ឋកិច្ចដោយផ្ទាល់ ពាក់

ព័ន្ធនឹងផលិតផលក្នុងស្រុកសរុបជាសកល ដោយសារគ្រោះមហន្តរាយ រួមទាំង គ្រោះមហន្តរាយពាក់ព័ន្ធនឹងទឹក ជាមួយនឹងការផ្តោតការយកចិត្តទុកដាក់លើ ការការពារប្រជាជនក្រីក្រ និងប្រជាជនដែលរស់នៅក្នុងស្ថានភាពងាយរងគ្រោះ។

១១.៦ ត្រឹមឆ្នាំ២០៣០ កាត់បន្ថយការបំពុលបរិស្ថានក្នុងមនុស្សម្នាក់នៅទីក្រុង រួមទាំងតាមរយៈការផ្តោតការយកចិត្តទុកដាក់លើ គុណភាពខ្យល់ និងការគ្រប់គ្រងសំណល់នៅទីក្រុង និងតំបន់ផ្សេងទៀត។

១១.៧ ត្រឹមឆ្នាំ២០៣០ ផ្តល់នូវការទទួលបានការប្រើប្រាស់ជាសកលទីលានសាធារណៈដែលមានពណ៌បៃតង មានសុវត្ថិភាព បរិយាប័ន្ន និងអាចប្រើប្រាស់បាន ជាពិសេស សម្រាប់ស្ត្រីនិងកុមារ ប្រជាជនមនុស្សចាស់ និងប្រជាជនដែលបាត់បង់សមត្ថភាពពលកម្ម។

១១.a គាំទ្រការភ្ជាប់ទំនាក់ទំនងវិជ្ជមាននៃសេដ្ឋកិច្ច សង្គមកិច្ច និងបរិស្ថាន រវាងតំបន់ទីប្រជុំជន និងតំបន់ជនបទដោយពង្រឹងការរៀបចំផែនការអភិវឌ្ឍន៍ជាតិនិងតំបន់។

១១.b ត្រឹមឆ្នាំ២០៣០ បង្កើនឲ្យបានច្រើននូវចំនួនទីក្រុងនិងការតាំងទីលំនៅថ្មី ដែលយល់ព្រមនិងអនុវត្តតាម គោលនយោបាយនិងផែនការសមាហរណកម្មដែលប្រកបដោយបរិយាប័ន្នការប្រើប្រាស់ធនធានមានប្រសិទ្ធភាព បន្ធូរបន្ថយនិងបន្សាំនឹងបម្រែបម្រួលអាកាសធាតុ មានភាពធន់នឹងគ្រោះមហន្តរាយ និងអភិវឌ្ឍនិងអនុវត្តឲ្យស្របតាមក្របខ័ណ្ឌទីក្រុងសេនដាយសម្រាប់កាត់បន្ថយហានិភ័យពីគ្រោះមហន្តរាយ ឆ្នាំ២០១៥-២០៣០ ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយទូទៅនៅគ្រប់កម្រិត។

១១.c គាំទ្របណ្តាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច រួមទាំងតាមរយៈ ជំនួយបច្ចេកទេសនិងហិរញ្ញវត្ថុ ក្នុងការកសាងអគារនានាដែលធុនរឹងមាំនិងប្រកបដោយចីរភាព ដោយប្រើប្រាស់វត្ថុធាតុដើមក្នុងស្រុក។

## គោលដៅទី១២៖ ធានាឲ្យមានចីរភាពក្នុងទម្រង់នៃការប្រើប្រាស់និងផលិតកម្ម

១២.១ អនុវត្តក្របខ័ណ្ឌ ១០ឆ្នាំ នៃកម្មវិធីផលិតកម្មនិងការប្រើប្រាស់ប្រកបដោយចីរភាពគ្រប់ប្រទេស ត្រូវអនុវត្តសកម្មភាព ដោយមានបណ្តាប្រទេសអភិវឌ្ឍន៍ជាអ្នកដឹកនាំ ដោយផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍ និងសមត្ថភាពនៃការអភិវឌ្ឍរបស់ប្រទេសនានា។

១២.២ ត្រឹមឆ្នាំ២០៣០ ការគ្រប់គ្រងប្រកបដោយចីរភាព និងប្រើប្រាស់ធនធានធម្មជាតិដោយមានប្រសិទ្ធភាព។

១២.៣ ត្រឹមឆ្នាំ២០៣០ កាត់បន្ថយជាសកលឲ្យបានពាក់កណ្តាលនៃម្ហូបអាហារដែលបោះបង់ចោលក្នុងមនុស្សម្នាក់ នៅម្រិតនៃការលក់រាយនិងនៅកម្រិតប្រើប្រាស់ និងកាត់បន្ថយការបាត់បង់ស្បៀងអាហារក្នុងសង្វាក់ផលិតកម្មនិងផ្គត់ផ្គង់ រួមទាំងការបាត់បង់ក្រោយពេលប្រមូលផល។

១២.៤ ត្រឹមឆ្នាំ២០២០ សម្រេចឲ្យបានការគ្រប់គ្រងបរិស្ថានល្អ ពាក់ព័ន្ធនឹងការបោះបង់ចោលសារធាតុគីមីនិងសំណល់គ្រប់ប្រភេទ តាមរយៈ ការកែច្នៃឡើងវិញ ឲ្យស្របតាមក្របខ័ណ្ឌកិច្ចកិច្ចព្រមព្រៀងអន្តរជាតិ និងកាត់បន្ថយឲ្យបានច្រើននូវការបញ្ចេញសំណល់ទាំងនោះទៅក្នុងបរិយាកាស ក្នុងទឹក និងក្នុងដី ដើម្បីកាត់បន្ថយឲ្យនៅទាបបំផុតនូវផលប៉ះពាល់អវិជ្ជមានរបស់វា លើសុខភាពប្រជាជននិងបរិស្ថាន

១២.៥ ត្រឹមឆ្នាំ២០៣០ កាត់បន្ថយឲ្យបានច្រើន ការបង្កើតសំណល់ តាមរយៈការការពារ ការកាត់បន្ថយ ការកែច្នៃឡើងវិញ និងការប្រើប្រាស់ឡើងវិញ។

១២.៦ លើកទឹកចិត្តក្រុមហ៊ុន ជាពិសេស បណ្តាក្រុមហ៊ុនធំៗនិងក្រុមហ៊ុនអន្តរជាតិ ឲ្យយល់ព្រមការអនុវត្តប្រកបដោយចីរភាព និងបញ្ចូលព័ត៌មានស្តីពីការធ្វើឲ្យមានចីរភាព ទៅក្នុងរបាយការណ៍ជាប្រចាំ។

១២.៧ លើកកម្ពស់ការអនុវត្តសវនកម្មជាសាធារណៈដែលមានចីរភាព ឲ្យស្របតាមគោលនយោបាយនិងអាទិភាពជាតិនានា។

១២.៨ ត្រឹមឆ្នាំ២០៣០ ធានាថា ប្រជាជននៅគ្រប់ទីកន្លែង ទទួលបានព័ត៌មាននិងចំណេះដឹងនានាដែលពាក់ព័ន្ធនិងសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងជីវភាពរស់នៅប្រកបដោយសុខដុមជាមួយធម្មជាតិ។

១២.a គាំទ្របណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងការពង្រឹងសមត្ថភាពវិទ្យាសាស្រ្តនិងបច្ចេកទេសរបស់ខ្លួន ដើម្បីឈានឆ្ពោះទៅរកទម្រង់ចីរភាពជាងមុននៃផលិតកម្មនិងការប្រើប្រាស់។

១២.b អភិវឌ្ឍនិងអនុវត្តឧបករណ៍នានា ដើម្បីតាមដានត្រួតពិនិត្យផលប៉ះពាល់នៃការអភិវឌ្ឍន៍ប្រកបដោយចីរភាព សម្រាប់វិស័យទេសចរណ៍ប្រកបដោយចីរភាព ដែលបង្កើតការងារនិងលើកកម្ពស់វប្បធម៌និងផលិតផលក្នុងស្រុក។

១២.c ពន្យល់បកស្រាយពីភាពគ្មានប្រសិទ្ធភាពនៃការឧបត្ថម្ភធនលើឥន្ធនៈហ្វូស៊ីល ដែលការប្រើប្រាស់នាំឲ្យមានសំណល់ច្រើន និងនាំឲ្យទីផ្សារមានការប្រែប្រួល ស្របតាមស្ថានភាពរបស់ប្រទេសជាតិនីមួយៗ រួមទាំង តាមរយៈ ការការប្រែការបង់ពន្ធ និងបំបាត់ជាបណ្តើរៗនូវការឧបត្ថម្ភធនទាំងនោះ នៅទីណាដែលមាន ដើម្បីឆ្លើយតបទៅនឹងផលប៉ះពាល់បរិស្ថានពីការប្រើប្រាស់ឥន្ធនៈនេះ ត្រូវផ្តោតការយកចិត្តទុកដាក់ពេញលេញលើតម្រូវការនិងលក្ខខណ្ឌជាក់លាក់ របស់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ និងកាត់បន្ថយឲ្យនៅកម្រិតទាបបំផុតផលប៉ះពាល់ជាអវិជ្ជមានដែលអាចមាន ទៅលើការអភិវឌ្ឍន៍ក្នុងរបៀបដែលការពារប្រជាជនក្រីក្រនិងផលប៉ះពាល់ដល់សហគមន៍។

## គោលដៅទី១៣៖ ចាត់វិធានការជាបន្ទាន់ ដើម្បីប្រយុទ្ធប្រឆាំងនឹងបម្រែបម្រួលអាកាសធាតុ និងផលប៉ះពាល់របស់វា

១៣.១ ពង្រឹងសមត្ថភាពធនទ្រាំនិងភាពបន្សាំទៅនឹងគ្រោះធម្មជាតិនិងគ្រោះមហន្តរាយពាក់ព័ន្ធនឹងអាកាសធាតុ សម្រាប់គ្រប់ប្រទេស។

១៣.២ ធ្វើសមាហរណកម្មការវាស់វែងបម្រែបម្រួលអាកាសធាតុ ទៅក្នុងគោលនយោបាយ យុទ្ធសាស្រ្ត និងផែនការជាតិ។

១៣.៣ លើកកម្ពស់ការអប់រំ ការលើកកម្ពស់ការយល់ដឹង និងលើកកម្ពស់សមត្ថភាពមនុស្សនិង ស្ថាប័ន ស្តីពីការបន្ធូរបន្ថយបម្រែបម្រួលអាកាសធាតុការបន្សាំ ការកាត់បន្ថយផលប៉ះពាល់ និង ការផ្តល់នូវការក្រើនរំលឹកឲ្យប្រយ័ត្នជាមុន។

១៣.a ត្រឹមឆ្នាំ២០២០ អនុវត្តនូវការប្តេជ្ញាចិត្ត ដែលជាការអនុវត្តដោយបណ្តាភាគីជាប្រទេសអភិវឌ្ឍន៍ ទៅនឹងអនុសញ្ញានៃក្របខ័ណ្ឌសហប្រជាជាតិស្តីពីបម្រែបម្រួលអាកាសធាតុ ដើម្បីសម្រេចគោលដៅនៃការកៀរគរមូលនិធិរួមគ្នាឲ្យបាន ១០០ពាន់លានដុល្លារក្នុងមួយឆ្នាំ ពីគ្រប់ប្រភព ដើម្បីដោះស្រាយនូវតម្រូវការរបស់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ នៅក្នុងបរិការណ៍នៃសកម្មភាពនានាសម្រាប់បន្ធូរបន្ថយនិងមានតម្លាភាពលើការអនុវត្ត និងកិច្ចប្រតិបត្តិការពេញលេញនូវ មូលនិធិបរិយាកាសពណ៌ខៀវ តាមរយៈ ការកៀរគរមូលធន ឲ្យបានឆាប់តាមតែអាចធ្វើទៅបាន

១៣.b ជំរុញយន្តការសម្រាប់លើកកម្ពស់សមត្ថភាព សម្រាប់ឲ្យផែនការនិងការគ្រប់គ្រងបញ្ហានានាពាក់ព័ន្ធនឹងបម្រែបម្រួលអាកាសធាតុ នៅក្នុងបណ្តាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច និងរដ្ឋដែនកោះតូចៗកំពុងអភិវឌ្ឍន៍ រួមទាំង ការផ្តោតការយកចិត្តទុកដាក់លើ ស្ត្រី យុវវ័យ និង សហគមន៍ប្រជាជនមូលដ្ឋាននិងប្រជាជនភាគតិច។

## គោលដៅទី១៤៖ អភិរក្សនិងប្រើប្រាស់ប្រកបដោយចីរភាពនូវ មហាសមុទ្រ សមុទ្រ និងធនធានសមុទ្រ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព

១៤.១ ត្រឹមឆ្នាំ២០៣០ ការពារ និងកាត់បន្ថយឲ្យបានច្រើនការបំពុលគ្រប់ប្រភេទនៅក្នុងសមុទ្រ ជាពិសេស ពីបណ្តាសកម្មភាពនានាដែលផ្តើមចេញពីលើដី រួមទាំង ការបំពុលដោយ សំណល់ក្នុងសមុទ្រ និងអាហារបំប៉ន។

១៤.២ ត្រឹមឆ្នាំ២០២០ គ្រប់គ្រងឲ្យបានច្រើន និងការពារប្រព័ន្ធអេកូឡូស៊ីនៅក្នុងសមុទ្រតាមឆ្នេរនិងទឹកសាបដើម្បីចៀសវាងផលប៉ះពាល់អវិជ្ជមាននានា រួមទាំង តាមរយៈការពង្រឹង ភាពធន់របស់វា និងដំណើរការសកម្មភាពសម្រាប់ធ្វើឲ្យមានភាពដូចដើមវិញ ដើម្បីសម្រេចឲ្យបាននូវមហាសាគរនិងដែនទឹកសាបដែលមានផលិតភាពនិងសុខភាព។

១៤.៣ កាត់បន្ថយឲ្យនៅកម្រិតទាបបំផុត និងដោះស្រាយពីផលប៉ះពាល់របស់អាស៊ីតកម្មមហាសមុទ្រ តាមរយៈ ការលើកកម្ពស់កិច្ចសហប្រតិបត្តិការផ្នែកវិទ្យាសាស្ត្រ នៅគ្រប់កម្រិត។

១៤.៤ ត្រឹមឆ្នាំ២០២០ អនុវត្តការប្រមូលផលត្រីត្រឹមត្រូវតាមច្បាប់ប្រកបដោយប្រសិទ្ធភាព និងលុបបំបាត់ការនេសាទលើសកម្រិតការនេសាទខុសច្បាប់គ្មានការអនុញ្ញាតិនិងគ្មានរបាយការណ៍ និងអនុវត្តផែនការគ្រប់គ្រងតាមបែបវិទ្យាសាស្ត្រដើម្បីបង្កើនបរិមាណផលត្រី ក្នុងរយៈពេលខ្លី ដែលអាចធ្វើទៅបាន យ៉ាងហោចណាស់ អាចផលិតបាន ទិន្នផលត្រីក្នុងកម្រិតបរិមាណនិរន្តភាព ដូចបានកំណត់ដោយលក្ខណៈជីវសាស្ត្រ។

១៤.៥ ត្រឹមឆ្នាំ២០២០ អភិរក្សយ៉ាងតិច ១០% នៃតំបន់ឆ្នេរតំបន់ក្នុងសមុទ្រ ស្របតាមច្បាប់ជាតិនិងអន្តរជាតិ និងផ្អែកលើព័ត៌មានវិទ្យាសាស្ត្រ

១៤.៦ ត្រឹមឆ្នាំ២០២០ ហាមឃាត់នូវទម្រង់ជាក់លាក់នៃការឧបត្ថម្ភធនលើការនេសាទ ដែលនឹងរួមចំណែកដល់ការការនេសាទលើសសមត្ថភាព លុបបំបាត់ការឧបត្ថម្ភធនដែលរួមចំណែកដល់ការនេសាទខុសច្បាប់ មិនផ្តល់របាយការណ៍ និងមិនស្របច្បាប់ និងទប់ទល់នឹងការឧបត្ថម្ភថ្មីៗដែលដូចគ្នានឹងការឧបត្ថម្ភធន ទទួលស្គាល់ថា ការធ្វើប្រព្រឹត្តកម្មផ្សេងៗគ្នានិងដោយឡែកប្រកបដោយសមស្របនិងមានប្រសិទ្ធភាព សម្រាប់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍និងបណ្តាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច គួរតែត្រូវបានបញ្ចូលទៅក្នុងផ្នែកនៃការចរចាពីការឧបត្ថម្ភធនដល់ការនេសាទ របស់អង្គការពាណិជ្ជកម្មពិភពលោក។

១៤.៧ ត្រឹមឆ្នាំ២០៣០ បង្កើនផលប្រយោជន៍ពីសេដ្ឋកិច្ចដល់បណ្តារដ្ឋដែនកោះតូចៗកំពុងអភិវឌ្ឍន៍និងបណ្តាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច ពីការប្រើប្រាស់ធនធានក្នុងសមុទ្រ ប្រកបដោយចីរភាព រួមទាំងតាមរយៈ ការគ្រប់គ្រងប្រកបដោយចីរភាពនូវការនេសាទ ជលវប្បកម្មនិងទេសចរណ៍។

១៤.a បង្កើនចំណេះដឹងផ្នែកវិទ្យាសាស្ត្រ អភិវឌ្ឍសមត្ថភាពស្រាវជ្រាវ និងផ្ទេរបច្ចេកវិទ្យាសមុទ្រផ្តោតការយកចិត្តទុកដាក់លើលក្ខខណ្ឌនិងការណែនាំរបស់គណៈកម្មការអន្តររដ្ឋាភិបាលសាករសាស្ត្រស្តីពីការផ្ទេរបច្ចេកវិទ្យាសមុទ្រ ដើម្បីធ្វើឲ្យប្រសើរឡើងសុខភាពសមុទ្រ និងលើកកម្ពស់ការចូលរួមរបស់ជីវចម្រុះសមុទ្រ ទៅក្នុងការអភិវឌ្ឍនៃបណ្តាប្រទេសកំពុង

អភិវឌ្ឍន៍ ជាពិសេសបណ្តារដ្ឋដែនកោះតូចៗកំពុងអភិវឌ្ឍន៍ និងបណ្តាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច។

១៤.b ផ្តល់នូវការទទួលបានធនធានសមុទ្រនិងទីផ្សារ ចំពោះអ្នកនេសាទទ្រង់ទ្រាយតូច។

១៤.c លើកកម្ពស់ការអភិរក្ស និងការប្រើប្រាស់សមុទ្រនិងធនធានក្នុងសមុទ្រប្រកបដោយចីរភាព តាមរយៈ ការអនុវត្តច្បាប់អន្តរជាតិ ដែលបានបង្ហាញនៅក្នុង UNCLOS ដែលផ្តល់នូវក្របខ័ណ្ឌគតិយុត្ត សម្រាប់ការអភិរក្សនិងប្រើប្រាស់សមុទ្រនិងធនធានក្នុងសមុទ្រ ប្រកបដោយចីរភាព ដូចបានបញ្ជាក់ក្នុងកថាខ័ណ្ឌទី១៥៨ នៃតម្រូវការរបស់យើងនាពេលអនាគត។

## គោលដៅទី១៥៖ ការពារ ស្តារ និងជំរុញការប្រប្រាស់ប្រកបដោយចីរភាពនូវប្រព័ន្ធអេកូឡូស៊ីនៅលើដែន គោក គ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព ប្រយុទ្ធប្រឆាំងនឹងឱនភាពដីបញ្ឈប់ និងបង្វែរទិសនៃការសឹករេចរឹលគុណភាពដី និងបញ្ឈប់កុំឲ្យបាត់បង់ជីវជាតិដីនិងជីវចម្រុះ

១៥.១ ត្រឹមឆ្នាំ២០២០ ធានាការអភិរក្ស ការស្តារនិងការប្រើប្រាស់ប្រកបដោយចីរភាពនូវប្រព័ន្ធអេកូឡូស៊ីក្នុងទឹកសាបនៅដែនកោះនិងនៅលើគោក និងសេវា ជាពិសេស ព្រៃឈើ ដីសើម ភ្នំ និងដីស្ងួត ឲ្យស្របតាមកតព្វកិច្ចក្រោមកិច្ចព្រមព្រៀងអន្តរជាតិ។

១៥.២ ត្រឹមឆ្នាំ២០២០ លើកកម្ពស់ការអនុវត្តការគ្រប់គ្រងប្រកបដោយចីរភាព នូវព្រៃឈើគ្រប់ប្រភេទ កាត់បន្ថយឲ្យបានពាក់កណ្តាលនូវការបំផ្លាញព្រៃឈើព្រៃឈើដែលបាត់បង់ និងបង្កើនឲ្យបានច្រើនជាសកលការដាំដើមឈើនិងការដាំព្រៃឈើឡើងវិញ

១៥.៣ ត្រឹមឆ្នាំ២០៣០ ប្រយុទ្ធប្រឆាំងនឹងការបំផ្លាញព្រៃឈើ ធ្វើឲ្យដូចដើមឡើងវិញដីដែលបាត់បង់ជីជាតិ រួមទាំង ដីដែលទទួលផលប៉ះពាល់ពី វាលរហោឋានកម្មភាពរាំងស្ងួត និងទឹកជំនន់ធ្វើឱ្យប្រសើរឡើងនូវ ពិភពលោកដែលមានដីមិនមានការខូចខាត។

១៥.៤ ត្រឹមឆ្នាំ២០៣០ ធានាការអភិរក្សប្រព័ន្ធអេកូឡូស៊ីនៅព្រៃភ្នំ រួមទាំងជីវចម្រុះនៅទីនោះ ដើម្បីលើកកម្ពស់សមត្ថភាពក្នុងការផ្តល់អត្ថប្រយោជន៍ចាំបាច់សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។

១៥.៥ អនុវត្តចំណាត់ការចាំបាច់និងជាបន្ទាន់ ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានលើលំនៅដ្ឋានធម្មជាតិ កាត់បន្ថយឲ្យបានពាក់កណ្តាលនូវការបាត់បង់ជីវចម្រុះ និង ត្រឹមឆ្នាំ២០២០ ការពារនិងបង្ការការបាត់បង់ផុតពូជនូវប្រភេទដែលគម្រាមកំហែងផុតពូជ។

១៥.៦ លើកម្ពស់ការបែងចែកដោយសមស្របនិងសមធម៌ នូវផលប្រយោជន៍ទទួលបានពីការប្រើប្រាស់ប្រភពនៃពូជនិងលើកកម្ពស់ការទទួលបានសមរម្យ នូវប្រភពទាំងនោះ ដូចបានឯកភាពជាអន្តរជាតិ

១៥.៧ អនុវត្តសកម្មភាពជាបន្ទាន់ដើម្បីបញ្ចប់ការបរបាញ់និងជួញដូរប្រភេទពូជ រុក្ខជាតិ និងពពួកសត្វដែលត្រូវបានការពារ និងដោះស្រាយទាំងតម្រូវការនិងការផ្គត់ផ្គង់ខុសច្បាប់នៃផលិតផលសត្វព្រៃ។

១៥.៨ ត្រឹមឆ្នាំ២០២០ ដាក់ឲ្យអនុវត្តវិធានការនានា ដើម្បីការពារការដាក់ឲ្យអនុវត្ត និងកាត់បន្ថយផលប៉ះពាល់ការរីករាលដាលនៃប្រភេទរុក្ខជាតិនិងសត្វពីបរទេស។

១៥.៩ ត្រឹមឆ្នាំ២០២០ បញ្ចូលតម្លៃប្រព័ន្ធអេកូឡូស៊ីនិងជីវចម្រុះ ទៅក្នុងផែនការជាតិនិងផែនការមូលដ្ឋាន ដំណើរការនៃការអភិវឌ្ឍ យុទ្ធសាស្ត្រនិងគណនេយ្យភាពសម្រាប់កាត់បន្ថយភាពក្រីក្រ។

១៥.a កៀរគរនិងបង្កើនឲ្យបានច្រើនធនធានហិរញ្ញវត្ថុពីគ្រប់ប្រភព ដើម្បីអភិរក្សនិងប្រើប្រាស់ប្រកបដោយចីរភាពជីវចម្រុះនិងប្រព័ន្ធអេកូឡូស៊ី។

១៥.b កៀរគរធនធានឲ្យបានច្រើនពីគ្រប់ប្រភពនិងនៅគ្រប់កម្រិត ដើម្បីផ្តល់ហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព និងផ្តល់នូវការឧបត្ថម្ភគ្រប់គ្រាន់ដល់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីអនុវត្តការគ្រប់គ្រងបានល្អប្រសើរ រួមទាំងសម្រាប់ការអភិរក្ស និងការដាំព្រៃឈើឡើងវិញ។

១៥.c លើកកម្ពស់ការគាំទ្រជាសកលដល់កិច្ចខិតខំប្រឹងប្រែងក្នុងការការពារការបរបាញ់ និងការជួញដូរប្រភេទពូជសត្វនិងរុក្ខជាតិដែលត្រូវបានការពារ រួមទាំង តាមរយៈការបង្កើនសមត្ថភាពដល់សហគមន៍មូលដ្ឋាន ដើម្បីស្វែងរកកាលានុវត្តភាពនៃការរស់នៅប្រកបដោយចីរភាព។

## គោលដៅទី១៦៖ លើកកម្ពស់សង្គមដែលមានសន្តិភាព ប្រកបដោយបរិយាប័ន្ន ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព ផ្តល់នូវការទទួលបានយុត្តិធម៌សម្រាប់ប្រជាជនគ្រប់រូប និងកសាងស្ថាប័នដែលមានប្រសិទ្ធភាព គណនេយ្យភាព និងបរិយាប័ន្ន នៅគ្រប់កម្រិត

១៦.១ កាត់បន្ថយឲ្យបានច្រើនរាល់ទម្រង់នៃអំពើហិង្សា និងអត្រាមរណភាពដោយអំពើហិង្សា នៅគ្រប់ទីកន្លែង។

១៦.២ លុបបំបាត់ការរំលោភបំពានការធ្វើអាជីវកម្ម ការជួញដូរ និងរាល់ទម្រង់នៃអំពើហិង្សានិងទារុណកម្មប្រឆាំងនឹងកុមារ

១៦.៣ លើកកម្ពស់វិធានការច្បាប់ នៅកម្រិតជាតិនិងអន្តរជាតិ និងធានាការទទួលបានយុត្តិធម៌ស្មើភាពគ្នា សម្រាប់ប្រជាជនគ្រប់រូប។

១៦.៤ ត្រឹមឆ្នាំ២០៣០ កាត់បន្ថយឲ្យបានច្រើននូវលំហូរហិរញ្ញវត្ថុនិងគ្រឿងសព្វាវុធខុសច្បាប់ ពង្រឹងការបានដូចដើមវិញ និងការទទួលបានមកវិញនូវអចលនទ្រព្យដែលត្រូវបានលួច និងប្រយុទ្ធប្រឆាំងនឹងអង្គការឧក្រិដ្ឋកម្មគ្រប់ទម្រង់។

១៦.៥ កាត់បន្ថយឲ្យបានច្រើន រាល់ទម្រង់នៃអំពើពុករលួយនិងការស៊ីសំណូក។

១៦.៦ រៀបចំស្ថាប័នឲ្យមានប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព នៅគ្រប់កម្រិត។

១៦.៧ ធានានូវការធ្វើសេចក្តីសម្រេច ដោយមានការចូលរួមពីគ្រប់តំណាង ដោយមានការទទួលខុសត្រូវប្រកបដោយបរិយាប័ន្ននៅគ្រប់កម្រិត។

១៦.៨ បើកទូលាយនិងពង្រឹងការចូលរួមរបស់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ នៅក្នុងស្ថាប័នអភិបាលកិច្ចសកល។

១៦.៩ ត្រឹមឆ្នាំ២០៣០ ផ្តល់អត្តសញ្ញាណផ្លូវច្បាប់ដល់ប្រជាជនគ្រប់រូប រួមទាំង ការចុះបញ្ជីកំណើត។

១៦.១០ ធានាការទទួលបានជាសាធារណៈ នូវព័ត៌មាននិងការការពារសិទ្ធិសេរីភាពមូលដ្ឋាន ឲ្យស្របតាមបទដ្ឋានគតិយុត្តជាតិ និងកិច្ចព្រមព្រៀងអន្តរជាតិ។

១៦.a ពង្រឹងបណ្តាស្ថាប័នពាក់ព័ន្ធជាតិ រួមទាំងតាមរយៈ កិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីកសាងសមត្ថភាពនៅគ្រប់កម្រិតជាពិសេស នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ សម្រាប់ទប់ស្កាត់អំពើហិង្សា និងប្រយុទ្ធប្រឆាំងនឹងអំពើភាវរកម្មនិងឧក្រិដ្ឋកម្ម។

១៦.b លើកកម្ពស់និងជំរុញការអនុវត្តច្បាប់និងគោលនយោបាយស្តីពី ការមិនរើសអើងសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។

## គោលដៅទី១៧៖ ពង្រឹងមធ្យោបាយអនុវត្តនានា និងបង្កើតភាពរស់រវើកនៃភាពជាដៃគូសកល សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព

១៧.១ ពង្រឹងការកៀរគរធនធានក្នុងស្រុក រួមទាំងតាមរយៈការគាំទ្រពីអន្តរជាតិដល់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីធ្វើឲ្យប្រសើរឡើងនូវសមត្ថភាពក្នុងស្រុកសម្រាប់ការប្រមូលពន្ធនិងចំណូលផ្សេងទៀត។

១៧.២ បណ្តាប្រទេសអភិវឌ្ឍន៍ត្រូវអនុវត្តនូវការសន្យារបស់ខ្លួន ក្នុងការផ្តល់ជំនួយអភិវឌ្ឍន៍ផ្លូវការ រួមទាំងការសន្យាដោយបណ្តាប្រទេសអភិវឌ្ឍជាច្រើន ក្នុងការធ្វើឲ្យសម្រេចបានចំណុចដៅនៃការផ្តល់ជំនួយអភិវឌ្ឍន៍ផ្លូវការ០,៧% នៃចំណូលជាតិសរុប ទៅដល់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ និងពី ០,១៥% ដល់ ០,២% នៃចំណូលជាតិសរុប ទៅដល់បណ្តាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច បណ្តាប្រទេសដែលផ្តល់ជំនួយអភិវឌ្ឍន៍ផ្លូវការ ត្រូវបានផ្តល់ការលើកទឹកចិត្តឲ្យពិចារណាកំណត់ចំណុចដៅ ក្នុងការផ្តល់ជំនួយនេះយ៉ាងតិច ០,២%នៃចំណូលជាតិសរុប ដល់បណ្តាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច។

១៧.៣ គៀរគរធនធានហិរញ្ញវត្ថុបន្ថែមទៀតពីប្រភពចម្រុះ សម្រាប់ផ្តល់ដល់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍។

១៧.៤ ជួយដល់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងការទទួលបានប្រកបដោយចីរភាពនូវបំណុលរយៈពេលវែង តាមរយៈគោលនយោបាយសម្របសម្រួល ដែលមានគោលបំណងជំរុញការផ្តល់បំណុលហិរញ្ញវត្ថុ ការបន្ធូរបន្ថយបំណុល ការកែទម្រង់បំណុលតាមតែអាចធ្វើទៅបាន និងដោះស្រាយបំណុលបរទេសរបស់បណ្តាប្រទេសក្រីក្រដែលជំពាក់បំណុលខ្ពស់ ដើម្បីកាត់បន្ថយភាពការភ័យព្រួយពីបំណុល។

១៧.៥ ទទួលយកនិងអនុវត្តរបបជំរុញការវិនិយោគ សម្រាប់បណ្តាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច។

១៧.៦ លើកកម្ពស់កិច្ចសហប្រតិបត្តិការជើង-ត្បូង កិច្ចសហប្រតិបត្តិការត្បូង-ត្បូង កិច្ចសហប្រតិបត្តិការតំបន់ត្រីកោណនិងកិច្ចសហប្រតិបត្តិការអន្តរជាតិ លើនិងការទទួលបាន វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងលើកកម្ពស់ការចែករំលែកការយល់ដឹងស្តីពីទម្រង់នៃការឯកភាពទាំងសងខាង រួមទាំងតាមរយៈការធ្វើឲ្យប្រសើរឡើង ការសម្របសម្រួលក្នុងចំណោមយន្តការដែលមានស្រាប់ ជាពិសេស ក្នុងកម្រិតសហប្រជាជាតិ និងតាមរយៈ យន្តការសម្របសម្រួលបច្ចេកវិទ្យាសកល។

១៧.៧ លើកកម្ពស់ការអភិវឌ្ឍ ការផ្ទេរ ការផ្សព្វផ្សាយ និងការផ្សាយចេញ នូវបច្ចេកវិទ្យាបរិស្ថានសមស្រប ដល់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងទម្រង់អនុគ្រោះ រួមទាំង ទម្រង់សម្បទាននិងការចូលចិត្ត ដូចបានឯកភាពគ្នាទៅវិញទៅមក។

១៧.៨ ត្រឹមឆ្នាំ២០១៧ធ្វើប្រតិបត្តិការពេញលេញ ធនាគារបច្ចេកវិទ្យានិងវិទ្យាសាស្ត្រ និងយន្តការកសាងសមត្ថភាពពី បច្ចេកវិទ្យានិងនវានុវត្តន៍ សម្រាប់បណ្តាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច និងលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាដែលមានសមត្ថភាព ជាពិសេសបច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍។

១៧.៩ លើកកម្ពស់ការគាំទ្រពីអន្តរជាតិ សម្រាប់ការអនុវត្តការកសាងសមត្ថភាពដែលបានកំណត់ចំណុចដៅនិងមានប្រសិទ្ធភាព ក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីគាំទ្រផែនការជាតិក្នុងការអនុវត្តនូវគ្រប់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព រួមទាំងតាមរយៈ កិច្ចសហប្រតិបត្តិការជើង-ត្បូង កិច្ចសហប្រតិបត្តិការត្បូង-ត្បូង និងកិច្ចសហប្រតិបត្តិការតំបន់ត្រីកោណ។

១៧.១០ លើកកម្ពស់ប្រព័ន្ធពាណិជ្ជកម្មចម្រុះ ដែលមានលក្ខណៈជាសកលមានមូលដ្ឋានច្បាប់ បើកទូលាយនិងសមធម៌ក្រោមអង្គការពាណិជ្ជកម្មពិភពលោក រួមទាំងតាមរយៈការសន្និដ្ឋាននៃការចរចាក្រោមរបៀបវារៈទីក្រុងដាហាស្តីពីការអភិវឌ្ឍ។

១៧.១១ បង្កើនឲ្យបានច្រើន ការនាំចេញរបស់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេស ត្រឹមឆ្នាំ ២០២០ ជាមួយនឹងទិដ្ឋភាពមួយដែលបង្កើនទ្វេដង~~ការ~~ចំណែកនៃការនាំចេញរបស់បណ្តាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច ទៅក្នុងការនាំចេញក្នុងសកលលោក។

១៧.១២ ធ្វើឲ្យសម្រេចបានទាន់ពេលនូវការអនុវត្ត ការលើកលែងពន្ធនិង ការទទួលបានកូតាទីផ្សារលើកលែងពន្ធលើមូលដ្ឋានចុងក្រោយ សម្រាប់បណ្តាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួចឲ្យស្របតាមការសម្រេចចិត្តរបស់អង្គការពាណិជ្ជកម្មពិភពលោក រួមទាំងតាមរយៈការធានាថាតួនាទីនៃការអនុគ្រោះ ចំពោះការអនុវត្តដើមដំបូងនៃនាំចេញពីបណ្តាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច មានលក្ខណៈតម្លាភាព ងាយស្រួល និងរួមចំណែកក្នុងសម្របសម្រួលការទទួលបានទីផ្សារ។

១៧.១៣ លើកកម្ពស់ស្ថិរភាព ម៉ាក្រូសេដ្ឋកិច្ចសកល រួមទាំង តាមរយៈការសម្របសម្រួលគោលនយោបាយ និងការបន្សុីគោលនយោបាយ។

១៧.១៤ លើកកម្ពស់ការបន្សុីគោលនយោបាយ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។

១៧.១៥ គោរពបរិយាកាសនិងការដឹកនាំគោលនយោបាយរបស់ប្រទេសនីមួយៗ ដើម្បីបង្កើតនិងអនុវត្តគោលនយោបាយនានា សម្រាប់ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍប្រកបដោយចីរភាព។

១៧.១៦ លើកកម្ពស់ភាពជាដៃគូសកល សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពការបំពេញបន្ថែមដោយភាពជាដៃគូដែលជាអ្នកមានចំណែកពាក់ព័ន្ធចម្រុះ ដែលកៀរគរនិងចែករំលែកចំណេះដឹងជំនាញបច្ចេកវិទ្យានិងធនធានហិរញ្ញវត្ថុ ដើម្បីគាំទ្រការសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅគ្រប់ប្រទេស ជាពិសេសបណ្ដាទេសកំពុងអភិវឌ្ឍន៍។

១៧.១៧ លើកទឹកចិត្តនិងលើកកម្ពស់ភាពជាដៃគូប្រកបដោយប្រសិទ្ធភាពក្នុងផ្នែកសាធារណៈ រវាងផ្នែកសាធារណៈនិងផ្នែកឯកជន និងជាមួយសង្គមស៊ីវិល កសាងភាពជាដៃគូផ្អែកលើបទពិសោធន៍និងយុទ្ធសាស្ត្រផ្ដល់ធនធាននៃភាពជាដៃគូ។

១៧.១៨ ត្រឹមឆ្នាំ២០២០ លើកកម្ពស់ការគាំទ្រការកសាងសមត្ថភាពដល់បណ្ដាប្រទេសកំពុងអភិវឌ្ឍន៍ រួមទាំងដល់បណ្ដាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច និងបណ្ដារដ្ឋដែនកោះតូចៗកំពុងអភិវឌ្ឍន៍ ដើម្បីបង្កើនឲ្យបានច្រើន ភាពអាចរកបានទាន់ពេលនៃទិន្នន័យដែលមានគុណភាពខ្ពស់ និងជឿជាក់បាន បំបែកតាមចំណូល យេនឌ័រ អាយុ ជាតិសាសន៍ ជនតិភាគតិច ស្ថានភាពនៃការផ្លាស់ប្ដូរទីលំនៅ ការបាត់បង់សមត្ថភាពពលកម្ម ទីតាំងភូមិសាស្ត្រ និងលក្ខណៈផ្សេងទៀតដែលពាក់ព័ន្ធ ក្នុងបរិការណ៍ជាតិ។

១៧.១៩ ត្រឹម២០៣០ កសាងដោយផ្អែកលើការផ្ដួចផ្ដើមដែលមានស្រាប់ ដើម្បីអភិវឌ្ឍមធ្យោបាយវាស់វែងពីវឌ្ឍនភាពនៃការអភិវឌ្ឍន៍ប្រកបដោយចីរភាព ដែលបំពេញផលិតផលក្នុងស្រុកសរុប និងគាំទ្រការកសាងសមត្ថភាពផ្នែកស្ថិតិ នៅក្នុងបណ្ដាប្រទេសកំពុងអភិវឌ្ឍន៍។



## គោលដៅទី ១៨៖ ការបោសសម្អាតមីន/សំណល់ជាតិផ្ទុះពីសង្គ្រាម និងការសង្គ្រោះជនរងគ្រោះ

១៨.១ បោសសម្អាតផ្ទៃដីចម្ការមីន/ស.ផ.ស.ដែលបានដឹងឲ្យអស់ត្រឹមឆ្នាំ២០៣០។

១៨.២ កាត់បន្ថយគ្រោះថ្នាក់ដោយសារមីន/ស.ផ.ស. នៅតិចជាង១០នាក់ក្នុងមួយឆ្នាំ ត្រឹមឆ្នាំ២០៣០

១៨.៣ លើកកម្ពស់សិទ្ធិ និងគុណភាពជីវិតរបស់ជនពិការដោយសារមីន/សំណល់ជាតិផ្ទុះពីសង្គ្រាមឲ្យបានកាន់តែប្រសើរឡើង។